ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ១២៥ ១៦៦ អ.ជ.ប.គ.ញ

ថ្ងៃចន្ទ ៤ កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០២០

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា
## និងលើកទិសដៅការងារខែកញ្ញា ឆ្នាំ២០២០

(ថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែសីហាឆ្នាំ២០២០)

ក្នុងខែសីហានេះ ទន្ទឹមនឹងការយកចិត្តទុកដាក់អនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែកក្កដា ឆ្នាំ២០២០ ក៏ដូចជាការបន្តអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥ ពិសេសអនុសាសន៍ណែនាំរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន** ក្នុងកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ កន្លងទៅ និងក្នុងដំណាក់កាលដែលប្រទេសជាតិកំពុងមមាញឹកក្នុងការទប់ស្កាត់ជំងឺឆ្លងរាតត្បាតកូវីដ-១៩ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងស្ថាប័នជាសមាជិក គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ វិស័យឯកជនវិស័យសាសនា។ល។ បានបន្តយកចិត្តទុកដាក់អនុវត្តសកម្មភាពបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន ដើម្បីរួមចំណែកថែរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារសុខុមាលភាពសង្គម ដោយទទួលបាននូវលទ្ធផលគួរឱ្យកត់សម្គាល់។ជាក់ស្តែង សភាពការណ៍គ្រឿងញៀន និងការងារដែលសម្រេចបាន ក៏ដូចជាការងារត្រូវបន្តអនុវត្តមានដូចខាងក្រោម៖

## I. សភាពការណ៍គ្រឿងញៀន

តាមរយៈលទ្ធផលនៃកិច្ចប្រតិបត្តិការរបស់កម្លាំងអនុវត្តច្បាប់ ក្នុងខែសីហានេះ សកម្មភាពចរាចរជួញដូរគ្រឿងញៀនខុសច្បាប់ នៅតែបន្តកើតមានឡើងនៅក្នុងភូមិសាស្ត្ររាជធានី-ខេត្ត ក្នុងនោះបទល្មើសជួញដូរគ្រឿងញៀនជាទ្រង់ទ្រាយធំ មានដូចជា ៖ កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន សហការជាមួយកម្លាំងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បង្ក្រាបបានករណីដឹកជញ្ជូន ជួញដូរគ្រឿងញៀនខុសច្បាប់០១ករណី នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ (ស្រី០១នាក់) ក្នុងនោះ ជាជនជាតិចិន០១នាក់ ភេទប្រុស និងជនជាតិថៃ០១នាក់ ភេទស្រី ចាប់យកវត្ថុតាងគ្រឿងញៀនប្រភេទមេតំហ្វេតាមីន(ICE) និងកេតាមីន(ketamine) បានជាង០២គីឡូក្រាម, កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន សហការជាមួយកម្លាំងស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ បង្ក្រាបបានករណីជួញដូរគ្រឿងញៀនខុសច្បាប់០១ករណី នៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ ឃាត់ខ្លួនជនសង្ស័យចំនួន០៥នាក់(ស្រី០២នាក់) ក្នុងនោះ ជាជនជាតិខ្មែរ ០៤នាក់ (ស្រី០១នាក់) និងជនជាតិវៀតណាម០១នាក់ ភេទស្រី ចាប់យកវត្ថុតាងគ្រឿងញៀនប្រភេទមេតំហ្វេតាមីន(ICE)បានជាង០១គីឡូក្រាម។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

ទន្ទឹមនេះ ការអនុវត្តវិធានការអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀន ក៏បានធ្វើសកម្មភាពយ៉ាងផុលផុស ដោយគ្របដណ្ដប់លើអ្នកទទួលសារអប់រំប្រមាណជាង **៣សែន ១ម៉ឺននាក់។** ការអនុវត្តវិធានការព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន តាមរយៈការព្យាបាលផ្អែកលើសហគមន៍ក្នុងប្រព័ន្ធសុខាភិបាលមូលដ្ឋាន យើងគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀនចំនួន **២៨៧នាក់។** ព្រមទាំងបានអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ នៅតាមសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ភោជនីយដ្ឋាន។ល។ បានចំនួន **១១លើក លើ ០២គោលដៅ។** ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ តាមរយៈការផ្លាស់ប្ដូរព័ត៌មាន និងចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមកតាមប្រព័ន្ធព័ត៌មានអនឡាញ ។

## I. ការដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងខែសីហានេះ បានបន្តអំពាវនាវឱ្យចូលរួមអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការទប់ស្កាត់ការឆ្លងរាតត្បាតជំងឺកូវីដ-១៩ និងបន្តយកចិត្តទុកដាក់លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយបានបញ្ជ្រាបការអប់រំផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងវេទិកានានារបស់**សម្ដេច។**

**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** តាមរយៈតំណាងរបស់**សម្ដេច** នៅក្នុងខែសីហានេះ បានបន្តអំពាវនាវដល់គ្រប់ស្រទាប់មហាជន សមត្ថកិច្ចអនុវត្តច្បាប់ ឲ្យខិតខំប្រើប្រាស់វិធានការជំនាញក្នុងការលុបបំបាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ដើម្បីរួមចំណែកឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល និងបានអំពាវនាវឱ្យមានការចូលរួមអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការទប់ស្កាត់ការឆ្លងរាតត្បាតជំងឺកូវីដ-១៩។

**សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងខែសីហានេះ បានបន្តអំពាវនាវឱ្យចូលរួមអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការទប់ស្កាត់ការឆ្លងរាតត្បាតជំងឺកូវីដ-១៩ និងផ្ដល់អនុសាសន៍ដឹកនាំឲ្យពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព គោលនយោបាយភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន បទបញ្ជាលេខ០១ ស្ដីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥របស់រាជរដ្ឋាភិបាល ។ ពង្រឹងការអនុវត្តវិធានការរដ្ឋបាល និងចាត់វិធានការបង្ក្រាបនៅតាមតំបន់ស្មុគស្មាញដែលពាក់ព័ន្ធនឹងគ្រឿងញៀន ។ ស្រាវជ្រាវ បង្ក្រាបករណីផលិតកែច្នៃគ្រឿងញៀន និងករណីដាំដុះដំណាំកញ្ឆា ។ ជាមួយគ្នានេះ ក៏បានធ្វើការអំពាវនាវឲ្យគ្រប់មជ្ឈដ្ឋានសង្គម និងកំលាំងអនុវត្តច្បាប់ទាំងអស់ អនុវត្តនូវទិសស្លោក ៣កុំ ១រាយការណ៍គឺៈ ១-កុំឲ្យពាក់ព័ន្ធ ២-កុំអន្តរាគមន៍ ៣-កុំលើកលែង និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន។

## II. ការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** ប្រធាន អ.ជ.ប.គ.ញ. បានបន្តដឹកនាំតាមគោលការណ៍សំខាន់ៗដែលបានដាក់ចេញ នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ និងកិច្ចប្រជុំបូកសរុបលទ្ធផលអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ កាលពីថ្ងៃទី១៦ ដល់ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ និងផ្អែកតាមស្មារតីនៃកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ កន្លងទៅ ក្នុងនោះរួមមាន ៖ ការបង្កើនការអប់រំផ្សព្វផ្សាយបង្ការ ទប់ស្កាត់បញ្ហាគ្រឿងញៀន, ការពង្រឹងវិធានការព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន, ការបង្កើនប្រសិទ្ធភាពអនុវត្តច្បាប់,ការពង្រឹងយន្តការសេនាធិការ

ប្រយុទ្ធប្រឆាំងគ្រឿងញៀនថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ, ការបន្តអនុវត្តឲ្យកាន់តែសកម្មនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥។ ជាមួយគ្នានេះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ. ក៏បានណែនាំ និងអំពាវនាវឱ្យមន្ត្រីរាជការ ប្រជាពលរដ្ឋ ចូលរួមបង្ការ ទប់ស្កាត់ការឆ្លងរាតត្បាតជំងឺកូវីដ-១៩(COVID-19) ឱ្យបានជាប្រចាំ និងតឹងរ៉ឹងបំផុត។

ក្រៅពីការដឹកនាំ និងផ្តល់នូវអនុសាសន៍ខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បាន៖

- អញ្ជើញដឹកនាំកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យអំពីវឌ្ឍនភាពនៃការសាងសង់ និងពិភាក្សាអំពីការត្រៀមដាក់ឱ្យដំណើរការនូវមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ នៅទីតាំងមជ្ឈមណ្ឌលជាតិតំបន់កែវផុស

- ជួបសំណេះសំណាល និងបានធ្វើការបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្សានុសិស្ស និងប្រជាពលរដ្ឋ នៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានចំនួន **៥.០០០**នាក់។

ជាមួយគ្នានេះ ឯកឧត្តម នាយឧត្តមសេនីយ៍ **ជួន សុវណ្ណ** អនុប្រធាន អ.ជ.ប.គ.ញ. បានអញ្ជើញដឹកនាំប្រតិភូអន្តរក្រសួងចុះទស្សនកិច្ច និងប្រជុំពិភាក្សាពីគោលរបបសម្រាប់ផ្តល់ជូនជនរងគ្រោះដែលកំពុងសម្រាកព្យាបាល នៅក្នុងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់កងពលតូចអន្តរាគមន៍លេខ៣១ នៅខេត្តកំពត ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆ្លើយតបទៅនឹងទិសដៅការងារដែលបានដាក់ចេញកាលពីខែកក្កដា ឆ្នាំ២០២០ និងយោងតាមការណែនាំជាប្រចាំរបស់**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តអនុវត្តការងារដោយទទួលលទ្ធផលសម្រេចបានដូចខាងក្រោម៖

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

អនុវត្តតាមគោលការណ៍ដឹកនាំ ឱ្យបង្កើនសកម្មភាពអប់រំ ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន បន្តជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ តាមរយៈបណ្តាញសង្គម បណ្តាញព័ត៌មាន គេហទំព័រ Facebook Page ការបញ្ចូលសារអប់រំអំពីបញ្ហាគ្រឿងញៀនទៅក្នុងសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ តាមទូរស័ព្ទចល័ត តាមរយៈស្ថានីយ៍វិទ្យុ និងទូរទស្សន៍រដ្ឋ និងឯកជន។ល។ បន្តជំរុញ និងបង្កើនសកម្មភាពអប់រំផ្សព្វផ្សាយ ទៅតាមវិធីសាស្ត្រ និងមធ្យោបាយផ្សេងៗ ក្រៅពីការរៀបចំកម្មវិធីប្រមូលផ្តុំជាទ្រង់ទ្រាយធំ នៅតាមមូលដ្ឋានឱ្យបានជាប្រចាំគ្រប់ទីកន្លែង និងដល់គោលដៅដែលងាយរងគ្រោះ ដូចជា ក្រុមយុវវ័យ កម្មករ ពលករ ពិសេសអ្នកបើកបររថយន្តដឹកទំនិញ និងដឹកអ្នកដំណើរ។ល។ និងចលនាឲ្យមានការចូលរួមពីគ្រប់សមាសភាពសង្គម បញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងគ្រប់វេទិកា និងព្រឹត្តិការណ៍ផ្សេងៗ ក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត យើងបានខិតខំប្រឹងប្រែងអនុវត្តការងារដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

**១.១. ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ**

- អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធីជជែកពិភាក្សាតាមទូទស្សន៍ ក្រោមប្រធានបទ ការបង្ការ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា នៅសាលថតរបស់ទីស្តីការក្រសួង

- តាមរយៈគេហទំព័ររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www. nacd.gov.kh) ក្នុងខែសីហា ឆ្នាំ២០២០ មានការចូលអានចំនួន **៣៩០,៨៥៩ដង**

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានផ្សព្វផ្សាយឃ្លីបវីដេអូខ្លីៗ ស្តីពីបញ្ហាគ្រឿងញៀន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមបណ្តាញទំនាក់ទំនងសង្គម Page Facebook របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយស្ថានីយទូរទស្សន៍ វិទ្យុ និងបណ្តាញព័ត៌មាន ដើម្បីធ្វើការអប់រំផ្សព្វផ្សាយ ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន។

**១.២. ការងារអប់រំតាមសហគមន៍**

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមវេទិកាសាធារណៈ តាមសហគ្រាស រោងចក្រ និងកម្មវិធីនានានៅក្នុងសហគមន៍មួយចំនួន។ល។

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានបន្តធ្វើសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងបង្ការ ទប់ស្កាត់ការឆ្លងរាតត្បាតនៃវីរុសកូវីដ-១៩(COVID-19) តាមបណ្តាញទំនាក់ទំនងសង្គម Page Facebook របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. និងមន្ត្រីជំនាញចូលរួមកិច្ចប្រជុំពិនិត្យ និងកែសម្រួលបញ្ចប់ខ្លឹមសារសម្ភារឧបទ្ទេសសម្រាប់ការរៀន និងបង្រៀន ស្តីពីការអប់រំបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ តាមគ្រឹះស្ថានសិក្សា ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា នៅសាលប្រជុំអគាររដ្ឋបាលចៅពញាហុក នៃទីស្តីការក្រសួង

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. និងមន្ត្រីជំនាញបានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាអប់រំផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលរៀបចំដោយក្រសួងបរិស្ថាន នៅសហគមន៍តំបន់ការពារធម្មជាតិចំបក់ ខេត្តកំពង់ស្ពឺ និងសហគមន៍តំបន់ការពារធម្មជាតិជីផាត់ ខេត្តកោះកុង ។

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ដល់ប្រជាពលរដ្ឋនៅថ្ងៃឈប់សម្រាកការងារនៅថ្ងៃទី១៧ ដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ ដើម្បីសងថ្ងៃសម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ តាមរយៈចង់ប្រជាពាក្យស្លោកតាមផ្លូវច្រកចេញ ចូល របស់រាជធានី-ខេត្ត ដែលមានអ្នកចូលរួមទទួលសារអប់រំប្រមាណជាង **៣៦,០០០នាក់**។

ជាមួយគ្នានេះ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនបានចំនួន **៩,៨៦៧លើក** ដោយគ្របដណ្តប់លើអ្នកមកទទួលយកសារ **២៧៥,៨៤៨នាក់/ស្រី ១៤១,៦៨៣នាក់** ក្នុងនោះ ៖ តាមរយៈគ្រឹះស្ថានសិក្សា ៤៦លើក អ្នកចូលរួម ១៤,៩៦៦នាក់/ស្រី ៨,៣៤១នាក់ តាមវេទិកាសាធារណៈ ៧,៤៨៨លើក អ្នកចូលរួម ២៥៥,៥៣៦នាក់/ស្រី ១៣០,៣៩៩នាក់, តាមរយៈវិស័យសាសនា ៦១លើក អ្នកចូលរួម ៤,៩៧៤នាក់/ស្រី ២,៨៦៧នាក់, តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ២,១៣៤លើក និងចុះចែកខិត្តប័ណ្ណ ១២៨លើក ស្មើនឹង ៨,៤១៧សន្លឹក និងនៅតាមរោងចក្រ សហគ្រាស ពន្ធនាគារ អង្គភាព ១០លើក អ្នកចូលរួម ៣៧២នាក់/ស្រី ៧៦នាក់។

- សរុបអ្នកដែលមកទទួលសារអប់រំនៅក្នុងខែកក្កដានេះមានប្រមាណ **៣១១,៨៤៨នាក់ ស្រី ១៤១,៦៨៣នាក់។**

ដោយឡែក ក្រសួងសាធារណការ និងដឹកជញ្ជូន បានបន្តស្នើសុំឲ្យក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ ធ្វើការណែនាំដល់អ្នកបើកបរយានយន្តកុំឲ្យប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង និងស្នើឲ្យបិទខិត្តប័ណ្ណ ផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមយានយន្ត និងជលយាន និងបង្កើន សកម្មភាពអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀននៅតាមស្ថានីយ៍ដឹកជញ្ជូនអចល័តរបស់ក្រសួង ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់បណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន

អនុវត្តតាមគោលការណ៍ដឹកនាំ ឲ្យពង្រឹងសមត្ថភាព គុណភាព និងប្រសិទ្ធភាព នៃការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម ដូចជាៈការជំរុញឱ្យបានសកម្មនូវដំណើរការព្យាបាលតាមសហគមន៍, ពង្រឹងសមត្ថភាពមណ្ឌលបណ្ដោះអាសន្នរដ្ឋ និងឯកជន ដោយពង្រឹងផ្នែកវេជ្ជសាស្ត្រ បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម កាត់បន្ថយការលាប់ឡើងវិញនូវការប្រើប្រាស់គ្រឿងញៀន , បង្កើតយន្តការដាក់លាក់ សម្រាប់ការធ្វើសមាហរណកម្ម និងការថែទាំបន្តនៅតាមឃុំ-សង្កាត់, បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកញៀន គ្រឿងញៀនឱ្យបានច្បាស់លាស់តាមបច្ចេកវិទ្យាទំនើបនាពេលបច្ចុប្បន្ន និងសហការជាមួយដៃគូពាក់ព័ន្ធដើម្បី ស្រាវជ្រាវរកវិធីសាស្ត្រព្យាបាលអ្នកញៀនគ្រឿងញៀនឱ្យកាន់តែល្អប្រសើរឡើង , គាំទ្រក្នុងការបញ្ជូនអ្នកប្រើ ប្រាស់គ្រឿងញៀនដែលមិនបានទទួលសេវាព្យាបាល ឱ្យទៅទទួលសេវាព្យាបាល ដោយប្រើប្រាស់គ្រប់យន្តការ ទាំងការអប់រំ លើកទឹកចិត្ត និងយន្តការអនុវត្តច្បាប់ ក៏ដូចជាការជំរុញការរៀបចំគោលការណ៍ដោះស្រាយភាព ចង្អៀតណែននៅតាមមណ្ឌលបណ្ដោះអាសន្នទៅតាមលក្ខណៈបច្ចេកទេស ដើម្បីទប់ស្កាត់ការរីករាលដាល ជំងឺកូវីដ-១៩ ។ ក្នុងខែសីហានេះ យើងបន្តអនុវត្តការងារដោយទទួលបាននូវលទ្ធផលដូចខាងក្រោម ៖

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន

- ក្រសួងសុខាភិបាល បន្តផ្តល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន ដល់អ្នកញៀន គ្រឿងញៀនប្រភេទអាភៀន(ហេរ៉ូអ៊ីន) នៅខែសីហានេះ មានអ្នកទៅទទួលសេវាព្យាបាលចំនួន ៧០នាក់ ស្រី ៩នាក់

- បន្តការគាំទ្រចំពោះអង្គការជាដៃគូ ដែលបាននិងកំពុងអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-ស៊ីរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីកាត់បន្ថយការឆ្លងមេរោគអេដស៍ និងរោគឆ្លងតាមឈាម ផ្សេងៗទៀត។

### ២.២. ការព្យាបាល និងស្តារនីតិសម្បទា

– បានជំរុញឲ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ពង្រឹង និងបង្កើតគណៈ កម្មការសម្របសម្រួលសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ តាមឃុំ-សង្កាត់ ដើម្បីជំរុញ និងគាំទ្រឲ្យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន មានភាពងាយស្រួលទៅទទួលយកសេវា ព្យាបាល នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្តនៅតាមសហគមន៍

– អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានរៀបចំកិច្ចប្រជុំពិភាក្សាលើបទបង្ហាញសម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល ស្តីពីការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន សម្រាប់មន្ត្រីដែលត្រូវ ទៅបម្រើការងារនៅមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀន គ្រឿងញៀន ខេត្តព្រះសីហនុ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

– អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយការិយាល័យក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ(ONCB) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនសម្រាប់មន្ត្រីសង្គមកិច្ចដែលត្រូវទៅបម្រើការងារ នៅមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀនខេត្តព្រះសីហនុ នៅភោជនីយដ្ឋានទន្លេបាសាក់២។

– អគ្គលេខាធិការ អ.ជ.ប.គ.ញ. និងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាការងារផ្តល់គោលរបបដល់ជនរងគ្រោះដែលកំពុងស្នាក់នៅព្យាបាល និងស្តារនីតិសម្បទាផ្តាច់ភាពញៀនគ្រឿងញៀន នៅមជ្ឈមណ្ឌលឱកាសថ្មី ខេត្តក្រចេះ និងនៅមជ្ឈមណ្ឌលនៃកងពលតូចអន្តរាគមន៍លេខ១១ ខេត្តកំពត ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

អនុវត្តតាមគោលការណ៍ដឹកនាំ ឲ្យបង្កើនប្រសិទ្ធភាពទប់ស្កាត់ និងការបង្ក្រាបជាអាទិភាពនូវការចរាចរឆ្លងកាត់គ្រឿងញៀនតាមតំបន់ព្រំដែន កម្ពុជា-ឡាវ កម្ពុជា-ថៃ កម្ពុជា-វៀតណាម ព្រលានយន្តហោះ និងបញ្ញើប្រៃសណីយ៍ ដោយផ្តោតទៅលើការពង្រឹងការប្រមូលព័ត៌មានពីគ្រប់ប្រភព សំដៅវែកមុខពួកឧក្រិដ្ឋជនទាំងនៅក្នុង និងក្រៅប្រទេស ឈានទៅបង្ក្រាបបាននូវបណ្តាញជួញដូរគ្រឿងញៀន និងយកចិត្តទុកដាក់ទៅលើគោលដៅប្រឈមនានា តំបន់ស្មុគស្មាញផ្សេងៗដែលមានបញ្ហាគ្រឿងញៀន ។ ក្នុងបរិបទនៃវិបត្តិជំងឺកូវីដ១៩ និងក្នុងស្ថានភាពដែលពិភពលោក ក៏ដូចនៅកម្ពុជា បានបិទព្រំដែន បិទការធ្វើដំណើរជាអន្តរជាតិ បិទទីតាំងសប្បាយដ្ឋាននានា។ល។ជាឱកាសដែលស្ថាប័នអនុវត្តច្បាប់របស់យើង មានលទ្ធភាពច្រើនក្នុងការបង្កើនការស្រាវជ្រាវ ស៊ើបអង្កេត បង្ក្រាបករណី ដើម្បីឈានទៅត្រួតត្រាបានសភាពការណ៍គ្រឿងញៀននៅផ្ទៃក្នុងប្រទេសបានល្អប្រសើរ និងបន្តជំរុញការចុះធ្វើតេស្តរកសារជាតុញៀនលើក្មេងទំនើង ជនមានតម្រុយប្រើប្រាស់គ្រឿងញៀន ពិសេសការឆ្មក់ត្រួតពិនិត្យអ្នកបើកបររថយន្តដឹកទំនិញ ដឹកកម្មករ ដឹកអ្នកដំណើរ ក៏ដូចជាការបន្តមានវិធានការច្បាប់ចំពោះក្រុមហ៊ុនដឹកជញ្ជូន ដែលមិនសហការជាមួយសមត្ថកិច្ច ហើយបណ្តែតបណ្តោយឲ្យមានការប្រើបំពានគ្រឿងញៀន ។ ក្នុងខែសីហានេះ យើងបន្តអនុវត្តការងារដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានរៀបចំកិច្ចប្រជុំស្តីពីការអនុវត្តផែនការសកម្មភាពក្រោមគម្រោងមូលនិធិ(LOA) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន រវាងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. និងការិយាល័យក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ(ONCB) សម្រាប់ឆ្នាំ២០២០ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

### ៣.២. លទ្ធផលបង្ក្រាបករណីគ្រឿងញៀន

ក្នុងខែសីហានេះ កិច្ចប្រតិបត្តិការបង្ក្រាបករណីគ្រឿងញៀនរួមមានដូចខាងក្រោម ៖

– **បទល្មើសគ្រឿងញៀនសរុប បង្ក្រាបបាន ៧៩៩ករណី** (ធៀបនឹងខែកក្កដា/២០២០, មាន ៩០៤ករណី) ថយចុះ ១០៥ករណី ស្មើនឹង ១១,៦% ក្នុងនោះ៖

- ករណីជួញដូរ រក្សាទុក ៥១៥ករណី
- ករណីប្រើប្រាស់ ២៧៩ករណី
- ករណីដាំដុះ ០៥ករណី

– **ជនសង្ស័យសរុប ឃាត់ខ្លួនមាន ១,៥៩៤នាក់ ស្រី ១១៣នាក់** (ធៀបខែកក្កដា/២០២០, មាន ១.៨១២នាក់) ថយចុះ ២១៨នាក់ ស្មើនឹង ១២% ក្នុងនោះ៖

- ជនសង្ស័យក្នុងករណីជួញដូរ រក្សាទុក ៩៤៧នាក់ (ស្រី ៨៦នាក់)
- ជនសង្ស័យក្នុងករណីប្រើប្រាស់គ្រឿងញៀន ៦៤៥នាក់ (ស្រី ២៥នាក់)
- ជនសង្ស័យក្នុងករណីដាំដុះ ០២នាក់ (ស្រី ០២នាក់)

ជនសង្ស័យរួមមាន ៖ ជនជាតិខ្មែរ ១,៥៧១នាក់ (ស្រី ១០៥នាក់) និងជនជាតិបរទេស ២៣នាក់ (ស្រី ០៨នាក់) ស្មើនឹង ០៣ជនជាតិ គឺ ៖ វៀតណាម ១១នាក់ (ស្រី ០៧នាក់), ចិន ០៩នាក់, និងថៃ ០៣នាក់ (ស្រី ០១នាក់) បានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត។

– **ជនសង្ស័យចាប់តាមដីកា** មានចំនួន ៥៧ដីកា ឃាត់ខ្លួនជនសង្ស័យចំនួន ៥៤នាក់ (ស្រី ០នាក់)។

– **គ្រឿងញៀនសរុប** ចាប់យកបានចំនួន ១១^គ.ក្រ ៨៧៣.៩៣^ក្រាម (ធៀបនឹងខែកក្កដា/២០២០, ៤១៦^គ.ក្រ ២៦៤.៣០^ក្រាម) ថយចុះ ៤០៤^គ.ក្រ ៣៩០.៣៧^ក្រាម ស្មើនឹង ៩៧,១% ក្នុងនោះ៖

- មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៩^គ.ក្រ ៧១៧.៨៥^ក្រាម
- មេតំហ្វេតាមីនគ្រាប់(WY) ១៦៧.៦៥^ក្រាម
- អ៊ិចស្តាស៊ី(MDMA) ៧៧៩.៣០^ក្រាម
- កេតាមីន ១^គ.ក្រ ២០៩.១៣^ក្រាម

– កញ្ឆាក្រៀមចំនួន ៣២១.៧៨ក្រាម

– **កញ្ឆាស្រស់ចំនួន ៨,២៦៧ដើម**

– **សម្ភារចាប់យក** ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត រួមមាន ៖ រថយន្តចំនួន ០៤គ្រឿង, ម៉ូតូចំនួន ២២៤គ្រឿង, ទូរសព្ទ ៧៦៥គ្រឿង, ជញ្ជីង ៤៩ គ្រឿង, ប្រាក់កម្ពុជាចំនួន ៦,៣១៨,៩០០រៀល, ប្រាក់អាមេរិក ៩៥០ដុល្លារ និងប្រាក់ថៃ ២០,០០០បាត។

**ក្នុងចំនួនករណីគ្រឿងញៀនខាងលើ** ៖

➢ ករណីគ្រឿងញៀនបង្ក្រាបដោយ **សមត្ថកិច្ចនគរបាលចំនួន ៦៧៧ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ១,៣២២នាក់ (ស្រី ៨៤នាក់)។

➢ ករណីគ្រឿងញៀនបង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថចំនួន ១២២ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ២៧២**នាក់** (ស្រី ២៩នាក់)។

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមជាអធិបតីក្នុងពិធីដុតបំផ្លាញចោលនូវសារធាតុញៀន និងគ្រឿងញៀនចំនួន ៤០គីឡូក្រាម ក្នុងឱកាសអបអរសាទទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តម កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅខេត្តស្វាយរៀង

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមជាអធិបតីក្នុងពិធីដុតបំផ្លាញចោលនូវសារធាតុញៀន និងគ្រឿងញៀនចំនួន១០០គីឡូក្រាម ក្នុងឱកាសអបអរសាទទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តម កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅខេត្តបន្ទាយមានជ័យ។

**៣.៣. ការអនុវត្តវិធានការរដ្ឋបាល ៖**

អនុវត្តវិធានការរដ្ឋបាលបានចំនួន **១១លើក** ក្នុងនោះ បានអញ្ជើញម្ចាស់អាជីវកម្ម និងអ្នកពាក់ព័ន្ធមកស្តាប់ការណែនាំអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀនបានចំនួន ១០លើក ស្មើនឹង ២៨២នាក់ ស្រី ១៥៥នាក់ បានចុះបិទទីតាំងអាជីវកម្មចំនួន **០១លើក** (ខារ៉ាអូខេ ០១លើក) ទន្ទឹមនោះ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានចុះធ្វើតេស្តរកសារធាតុញៀនលើក្មេងទំនើង ជនមានតម្រុយប្រើប្រាស់គ្រឿងញៀន និងធ្មក់ត្រួតពិនិត្យអ្នកបើកបររថយន្តដឹកទំនិញ ដឹកកម្មករ ដឹកអ្នកដំណើរ បុគ្គលិកក្លឹបកម្សាន្ត កាស៊ីណូ សណ្ឋាគារ ខារ៉ាអូខេ សរុបចំនួន ៩៩លើក ស្មើនឹង ៧២៤នាក់/ស្រី ០នាក់ **រកឃើញអ្នកផ្ទុកសារធាតុញៀន** ១៧៥នាក់ ត្រូវបានសមត្ថកិច្ចធ្វើការបញ្ជូនតាមនីតិវិធីច្បាប់ឲ្យទៅទទួលយកសេវាបន្សាប និងព្យាបាល។

**៣.៤. លទ្ធផលកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន**

– សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសលវិច័យក្នុងខែសីហា ឆ្នាំ២០២០ មានចំនួន **៩០៣ករណី** ស្មើនឹង ៩៩៣**សំណាក** ក្នុងនោះ៖

- **សំណាកវិជ្ជមានសារធាតុញៀន** មានចំនួន **៩៦៧សំណាក** (៩៧,៣៦%) គឺ៖
  - ➢ មេតំហ្វេតាមីនគ្រាប់ (WY) ២៣សំណាក = ២,៣១%
  - ➢ មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៨៨៥សំណាក = ៨៩,១២%
  - ➢ សារធាតុញៀនប្រភេទ (កេតាមីន) ២០សំណាក = ២,០១%
  - ➢ សារធាតុញៀនប្រភេទ (អ៊ិចស្តាស៊ី) ២៩សំណាក = ២,៩២%
  - ➢ សារធាតុញៀនប្រភេទ (នីមេតាហ្សេប៉ាម) ៤សំណាក = ០,៤០%
  - ➢ សារធាតុញៀនប្រភេទ (ហេរ៉ូអ៊ីន) ៥សំណាក = ០,៥០%
  - ➢ សារធាតុញៀនប្រភេទ (កញ្ឆា) ១សំណាក = ០,១០%
- **សំណាកអវិជ្ជមានសារធាតុញៀន = ២៦សំណាក** (២,៦១%)។

– ផ្តល់តេស្តរកសារធាតុញៀនឈ្មោះ (ម៉ាគីតេស្ត)ចំនួន ៦០០តេស្ត តេស្តរកសារធាតុញៀនក្នុងទឹកមូត្រឈ្មោះ(មេតំហ្វេតាមីន)ចំនួន ៤៨០តេស្ត និងតេស្តរកសារធាតុញៀនឈ្មោះ(កេតាមីនតេស្ត) ចំនួន ១០០តេស្ត ដល់អង្គភាពចំនួន ០៥ គឺ មន្ទីរប្រឆាំងគ្រឿងញៀន ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ នាយកដ្ឋានកណ្តាលយុត្តិធម៌ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

បានបន្តជំរុញឱ្យក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រៀបចំវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកក្រុមហ៊ុន រោងចក្រ ដែលមានប្រតិបត្តិការពាក់ព័ន្ធនឹងសារធាតុគីមីផ្សំ ឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីការគ្រប់គ្រង និងត្រួតពិនិត្យសារធាតុគីមីផ្សំ។ ជំរុញឱ្យមានអ្នកទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសារធាតុគីមីផ្សំ សម្រាប់ផលិតកម្មក្រុមហ៊ុន រោងចក្ររបស់ពួកគេ។ ជំរុញការចុះធ្វើអធិការកិច្ចនៅតាម ក្រុមហ៊ុន រោងចក្រ សហគ្រាសដែលប្រើប្រាស់សារធាតុគីមីផ្សំ ដើម្បីពិនិត្យមើលសៀវភៅបន្ទុក និងវាយតម្លៃពីហានិភ័យនានា ដែលអាចកើតមានដោយការបង្វែរសារធាតុគីមីផ្សំទៅផលិតគ្រឿងញៀនខុសច្បាប់។ជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការប្រមូលព័ត៌មាន និងត្រួតពិនិត្យឯកសារការអនុញ្ញាតឲ្យនាំចូលនូវ

សារធាតុញៀន និងសារធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាង៤បសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជាក់ស្តែងក្នុងខែសីហាឆ្នាំ២០២០ យើងគ្រប់គ្រងបាននូវសារធាតុញៀន និងសារធាតុគីមីផ្សំសរុបចំនួន ១,៥៥៨,៤១៥ គ.ក្រ ២០០០ ក្រាម និង៣០០០ មីលីក្រាម ដែលស្ថិតក្នុង៖

- តារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៖
  - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុគីមីផ្សំចំនួន ១៩៨,២៤០ គ.ក្រ
  - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុគីមីផ្សំចំនួន ១,៣៦០.០០០ គ.ក្រ។
- តារាងទី២ ទី៣ និងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៖
  ក្រសួងសុខាភិបាល បានផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុញៀន ជាវត្ថុធាតុដើម ចំនួន ១៧៥ គ.ក្រ និងឱសថមានផ្ទុកសារធាតុញៀនចំនួន ២០០០ ក្រាម និង ៣០០០ មីលីក្រាម។

ក្នុងខែសីហានេះដែរ ៖

– អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានរៀបចំកិច្ចប្រជុំក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ក្នុងគោលបំណងពង្រឹង និងជំរុញយន្តការគ្រប់គ្រងត្រួតពិនិត្យការនាំចូល ការនាំចេញ ការប្រើប្រាស់សារធាតុគីមីផ្សំស្ថិតក្រោមបញ្ញត្តិនៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទប់ស្កាត់ការបង្វែរពីគោលដៅប្រើប្រាស់ស្របច្បាប់ យកទៅលួចលាក់សំយោគកែច្នៃផលិតគ្រឿងញៀនខុសច្បាប់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

– ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជប.គ.ញ. រួមជាមួយមន្ត្រីជំនាញ បានចូលរួមក្នុងក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដើម្បីចុះត្រួតពិនិត្យ ដកពិសោធន៍ការគ្រប់គ្រង ការប្រើប្រាស់សារធាតុគីមីផ្សំនៅក្រុមហ៊ុន Hunan ER-Kang (Cambodia) Co,.LTD នៅភូមិតាគ្រក់ ឃុំត្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

បានបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តស្មារតីនៃកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសថៃ ឡាវ និងប្រទេសវៀតណាម រួមមាន៖

**៥.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយភាគីថៃ និងភាគីឡាវ បន្តពង្រឹងយន្តការភូមិ ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀនរវាងខេត្តព្រះវិហារ ជាមួយខេត្តអូរប៊ុន និងរវាងខេត្តស្ទឹងត្រែង ជាមួយខេត្តចំប៉ាសាក់។

**៥.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្ត ពង្រឹងប្រសិទ្ធភាពការងារការិយាល័យទំនាក់ទំនងព្រំដែន(**BLO**) ជាមួយប្រទេសជិតខាង។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

បានបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសនានាក្នុងតំបន់ ក្នុងសកលលោក និងដៃគូអភិវឌ្ឍន៍នានា តាមគ្រប់យន្តការ ទ្វេភាគី ត្រីភាគី ពហុភាគី ដើម្បីទប់ស្កាត់ការចរាចរ និងការប្រើប្រាស់គ្រឿងញៀន ក៏ដូចជាការបន្តកិច្ចសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ ដើម្បីគាំទ្រការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា ។ ក្នុងខែសីហានេះ យើងបន្តអនុវត្តការងារដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**៦.១.** អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានទទួលជួបពិភាក្សាការងារជាមួយមន្ត្រីនគរបាលជាន់ខ្ពស់នៃស្ថាប័ននគរបាលសហព័ន្ធអូស្ត្រាលី ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន និងបណ្តុះបណ្តាលធនធានមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

**៦.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) បានរៀបចំកិច្ចប្រជុំពិភាក្សាលម្អិតក្នុងការត្រៀមបង្កើតវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល និងមន្ត្រីអនុវត្តច្បាប់នៅតាមបណ្តោយព្រំដែន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

**៦.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC)បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញក្នុងគោលបំណងពិភាក្សាក្នុងការបង្កើតវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល និងមន្ត្រីអនុវត្តច្បាប់តាមបណ្តោយព្រំដែន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

អនុវត្តតាមគោលការណ៍ដឹកនាំ ឲ្យពង្រឹងយន្តការសេនាធិការ ដើម្បីអនុវត្តការដឹកនាំពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងដើម្បីជំរុញប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យទទួលបានលទ្ធផលល្អប្រសើរ ធានាបាននូវនិរន្តរភាពទាំងការងារតាមដានបូកសរុបរបាយការណ៍ និងវាយតម្លៃសភាពការណ៍គ្រឿងញៀន ក៏ដូចជាការបន្តអនុវត្តគោលនយោបាយលើកទឹកចិត្តដល់អង្គភាព បុគ្គលមានស្នាដៃពិតប្រាកដក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងវិស័យឯកជនផងដែរ ។ ក្នុងខែសីហានេះ យើងបន្តអនុវត្តការងារទទួលដោយបាននូវលទ្ធផលដូចខាងក្រោម៖

**៧.១.** អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងាររបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រចាំកក្កដា និងលើកទិសដៅការងារខែសីហា ឆ្នាំ២០២០ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ។

**៧.២.** ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. រួមជាមួយមន្ត្រីជំនាញ បានទៅចូលរួមនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ឆ្នាំ២០២០ នៅខេត្តមណ្ឌលគីរី រតនគីរី និងខេត្តស្ទឹងត្រែង ។

**៧.៣.** អគ្គលេខាធិកាដ្ឋាន អ.ជ.ប.គ.ញ. បាន និងកំពុងបន្តនីតិវិធីរៀបចំសេចក្តីព្រាងគោលនយោបាយ ជាតិសម្រាប់ការបង្កើតភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន

**ជាមួយគ្នានេះ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចូលរួមក្នុងការងារផ្សេងៗ រួមមាន៖**

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង OCSE ដើម្បីពិនិត្យផ្តល់យោបល់លើកម្រងសំនួរ នៃការសិក្សាស្រាវជ្រាវជាសកលស្តីពី "ការបញ្ឈប់គ្រោះថ្នាក់(Disrupting Harm)" លើការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅភោជនីយដ្ឋានទន្លេបាសាក់២

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសនៃគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការសម្រាប់អនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅសាលប្រជុំសាលាខេត្តព្រះសីហនុ

- អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានចូលរួមក្នុងពិធីប្រកាសចូលកាន់មុខតំណែងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

- អគ្គលេខាធិការ អ.ជ.ប.គ.ញ. ចូលរួមក្នុងពិធីប្រកាសចូលកាន់មុខតំណែងបំពាក់ឋានន្តរស័ក្តិ និងគ្រឿងឥស្សរិយយសជូនមន្ត្រីគណៈកម្មាធិការប្រឆាំងទារុណកម្ម ក្រោមអធិបតីភាពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ ។

## IV. ទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញាឆ្នាំ២០២០

ដើម្បីអនុវត្តបន្តឲ្យមានប្រសិទ្ធភាពលើការងារត្រួតពិនិត្យគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានដាក់ចេញនូវទិសដៅការងារសម្រាប់**ខែកញ្ញាឆ្នាំ២០២០** ដូចខាងក្រោម៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តការចុះចែកកូនសៀវភៅអប់រំ សៀវភៅចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន ខិត្តប័ណ្ណអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន បិទផ្ទាំងរូបភាពអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន សៀវភៅកំរង សំណួរ-ចម្លើយពីគ្រឿងញៀន ពិសេសការបោះពុម្ព និងផ្សព្វផ្សាយទិសស្លោករបស់**សម្តេចក្រឡាហោម ស ខេង** ៣កុំ ១រាយការណ៍ នៅតាមក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានសិក្សា រោងចក្រ សហគ្រាស ការដ្ឋានសំណង់ កសិដ្ឋាន លំនៅដ្ឋាន កម្មករ និងលើយានយន្ត។ល។

**១.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តការងារអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់ក្រុមគោលដៅប្រឈម និងងាយប្រឈមនឹងគ្រោះថ្នាក់ ដូចជាក្រុមយុវវ័យ ពលករចល័ត ពលករចំណាក ស្រុក កម្មករសំណង់ កម្មកររោងចក្រ កម្មករក្រៅប្រព័ន្ធ អ្នកបើកបររថយន្តដឹកទំនិញ និងដឹកអ្នកដំណើរ និងទីតាំងសប្បាយដ្ឋាននានា ក៏ដូចជាបន្តជំរុញការបណ្តុះបណ្តាលចាត់តាំងចងក្រងក្រុមជនបង្គោល និងការបណ្តុះបណ្តាលអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនដល់មន្ត្រីក្រោមឱវាទ នៅផ្ទៃក្នុងក្រសួង ស្ថាប័ន អង្គភាព។

**១.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម ក្នុងពិធីឈប់សម្រាក និងព្រឹត្តការណ៍សង្គមផ្សេងៗក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត។

**១.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំបណ្ណាល័យឌីជីថលអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀននៅបណ្ណាល័យសម្តេចតេជោ ហ៊ុន សែន០១កន្លែង និងនៅសាលាធនធានចំនួន០៩កន្លែង។

**១.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ផលិតឧបទ្ទេសសិក្សា ដូចជា សៀវភៅសិក្សាគោល ស្តីពីគ្រឿងញៀន និងសុវត្ថិភាពនៃការអភិវឌ្ឍ សៀវភៅ ស្តីពី

វិធីសាស្ត្រនៃការបង្រៀន និងការបណ្តុះបណ្តាលគ្រូបង្រៀន នៅតាមគ្រឹះស្ថានគរុកោសល្យខេត្ត និងវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ។

**១.៦.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តអភិវឌ្ឍខ្លឹមសារមេរៀន ស្តីពីការបង្ការបញ្ហាគ្រឿងញៀន និងវិធីបង្រៀនសម្រាប់ដាក់ចូលទៅក្នុងសៀវភៅសិក្សាគោល និងមុខវិជ្ជាអប់រំសុខភាព សម្រាប់ថ្នាក់អប់រំមូលដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាការរៀបចំខ្លឹមសារមេរៀន ស្តីពីការបង្ការបញ្ហាគ្រឿងញៀនសម្រាប់កម្មវិធីបណ្តុះបណ្តាលធនធានមនុស្សទាំងនៅក្នុងក្របខណ្ឌស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ។

**១.៧.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដើម្បីផ្សព្វផ្សាយច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, សភាពការណ៍គ្រឿងញៀន, ចំណេះដឹងជាមូលដ្ឋានអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមតំបន់គោលដៅសំខាន់ៗដែលងាយរងគ្រោះដោយសារគ្រឿងញៀន។

**១.៨.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តរៀបចំវេទិកាតុមូលដើម្បីអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥។

**១.៩.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តរៀបចំវេទិកាជួបជាមួយវិស័យឯកជន ដើម្បីអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥។

**១.១០.**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសហការជាមួយស្ថានីយទូរទស្សន៍ វិទ្យុ និងបណ្តាញសារព័ត៌មានអេឡិចត្រូនិកដើម្បីធ្វើការផ្សព្វផ្សាយពីការងារដែលទាក់ទងនឹងបញ្ហាគ្រឿងញៀន។

**១.១១.**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តបញ្ជូនសារអប់រំផ្សព្វផ្សាយតាមទូរស័ព្ទចល័ត តាមរយៈសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌តាមរយៈស្ថានីយ៍វិទ្យុ និងទូរទស្សន៍ តាមគេហទំព័ររបស់ក្រសួងស្ថាប័នរដ្ឋ ពិសេសតាមរយៈPage Facebook របស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់។

**១.១២.**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តចលនាឲ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយ ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន។

**១.១៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តបោះពុម្ពខិត្តប័ណ្ណអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន សម្រាប់អប់រំផ្សព្វផ្សាយទៅលើក្រុមគោលដៅដែលងាយរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន។

**១.១៤.**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញ និងសម្របសម្រួលជាមួយក្រុមហ៊ុន និងវិស័យឯកជន ដើម្បីធ្វើសកម្មភាពផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងកម្មវិធីផ្សេងៗ និងទិវាបុណ្យជាតិសំខាន់ៗ។

**១.១៥.**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមសកម្មភាពអប់រំផ្សព្វផ្សាយ ស្តីពីបញ្ហាគ្រឿងញៀន ក្នុងពិធីបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ ប្រពៃណីជាតិខ្មែរ។

**១.១៦.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមរៀបចំផែនការបណ្តុះបណ្តាលគ្រូបង្គោលនៅតាមបណ្តាក្រសួង-ស្ថាប័ន អង្គភាព ជាពិសេសតាមបណ្តាខេត្ត។

## ២. ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន

**២.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឲ្យកាន់តែសកម្ម ដើម្បីឲ្យអ្នករងគ្រោះដោយសារគ្រឿងញៀន បានដឹងភ្ញាក់រលឹក និងស្ម័គ្រចិត្តទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព។

**២.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ជំរុញ និងពង្រឹងសមត្ថភាព គុណភាព នៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្ន សម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

**២.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសហការរៀបចំ និងពង្រឹងមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពឱ្យមានលទ្ធភាព និងសមត្ថភាពអាចទទួលព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ បណ្តារាជធានី-ខេត្ត ក៏ត្រូវរៀបចំយន្តការគាំទ្រចំពោះដំណើរការព្យាបាលនេះផងដែរ។

**២.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តពង្រឹងគណៈកម្មការសម្របសម្រួលដល់ការព្យាបាលអ្នកញៀនគ្រឿងញៀន ក្នុងសហគមន៍ នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញ និងគាំទ្រឲ្យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀនមានភាពងាយស្រួលទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព-មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្តនៅតាមសហគមន៍។

**២.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ជំរុញការដាក់ឱ្យដំណើរការនូវមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ ឱ្យបានក្នុងខែវិច្ឆិកាឆ្នាំ២០២០ខាងមុខ។

**២.៦.** អគ្គលេខាធិកាដ្ឋាន អ.ជ.ប.គ.ញ. ជំរុញការរៀបចំគោលការណ៍ណែនាំសម្រាប់ការបញ្ជូនអ្នកញៀនគ្រឿងញៀនមណ្ឌលបណ្តោះអាសន្នដែលមានការចង្អៀតណែន ទៅមជ្ឈមណ្ឌលជាតិនៅខេត្តព្រះសីហនុ។

**២.៧.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ពង្រឹងការអនុវត្តវិធានគម្លាតសង្គម និងវិធានអនាម័យនានាក្នុងមណ្ឌលបណ្តោះអាសន្នសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀន ក្នុងដំណាក់កាលនៃវិបត្តិន៍ជំងឺកូវីដ-១៩ ។

**២.៨.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញការរៀបចំសេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ដែលជាទណ្ឌិតនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ។

**២.៩.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តចលនា និងផ្តល់ការសម្របសម្រួលឲ្យមានការចូលរួមពីវិស័យឯកជន លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

**២.១០.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមចុះត្រួតពិនិត្យមណ្ឌលព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន របស់រដ្ឋ និងឯកជន។

**២.១១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តអនុវត្តការងារជាមួយអង្គការ Aids Care China លើការងារព្យាបាលអ្នកញៀនគ្រឿងញៀនតាមសហគមន៍។

**២.១២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញលេខាធិការដ្ឋានគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដាក់របៀបវារៈកិច្ចប្រជុំឆ្លងការងារកំណត់លក្ខខណ្ឌសម្រាប់ការព្យាបាលអ្នកញៀនតាមសហគមន៍ មណ្ឌលជាតិ និងមណ្ឌលបណ្តោះអាសន្ន។

**២.១៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសម្របសម្រួលបញ្ជូនឯកសារព្រាងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្របសម្រួលលើកញ្ចប់ថវិកាសម្រាប់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

**៣.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តពង្រឹងសមត្ថភាព ឆន្ទៈ គុណធម៌ស្មោះត្រង់នឹងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់តាមទិសស្លោកកុំ៣ ១រាយការណ៍របស់ **សម្តេចក្រឡាហោម ស ខេង** គឺ ៖ ១-កុំឲ្យពាក់ព័ន្ធ ២-កុំអន្តរាគមន៍ ៣-កុំលើកលែង និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន។

**៣.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៥។

**៣.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តគាំទ្រយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូង និងការចង្អៀតណែននៅក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី-ខេត្ត។

**៣.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រី អនុវត្តច្បាប់គ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) និងតាមប្រព័ន្ធអេឡិចត្រូនិក (e-Learning) នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. និងតាមបណ្តាខេត្ត។

**៣.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមជួបពិភាក្សាការងារជាមួយសមាជិកដែលពាក់ព័ន្ធអំពីការអនុវត្តគម្រោង PATROL នៅតាមច្រកទ្វារព្រំដែនអន្តរជាតិនីមួយៗ។

**៣.៦.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់លើការងារត្រួតពិនិត្យគ្រឿងញៀននៅប្រទេសកម្ពុជា សម្រាប់ខែកញ្ញាឆ្នាំ២០២០។

**៣.៧.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តរៀបចំវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់មេឃុំ ចៅសង្កាត់ នាយប៉ុស្តិ៍នគរបាល និងមន្ត្រីទទួលបន្ទុកការងារគ្រឿងញៀននៅតាមមូលដ្ឋាន។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

**៤.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងត្រួតពិនិត្យសារជាតុគីមីផ្សំ វត្ថុធាតុដើម ព្រមទាំងសារជាតុផ្សំផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់។

**៤.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិក ក្រុមហ៊ុនឧស្សាហកម្មគីមី រោងចក្រសហគ្រាស ឲ្យមានការយល់ដឹងពីសារជាតុគីមីផ្សំដែលអាចបង្វែរយកទៅផលិតជាគ្រឿងញៀនខុសច្បាប់។

**៤.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់។

**៤.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តកិច្ចសហការប្រមូលព័ត៌មានពាក់ព័ន្ធ នឹងការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ។

**៤.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តសម្របសម្រួលជាប្រចាំជាមួយក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការផ្តល់របាយការណ៍ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យលើការស្នើសុំការអនុញ្ញាតនាំចូលនូវសារធាតុគីមីផ្សំ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

**៥.១.** បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន តាមគ្រប់យន្តការទាំងទ្វេភាគីត្រីភាគីពហុភាគី ដើម្បីទប់ស្កាត់ការចរាចរជួញដូរគ្រឿងញៀននៅតាមព្រំដែន។

**៥.២.** បន្តការពង្រឹងយន្តការ និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO) ពិសេសការកសាង **ភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន** នៅតាមបណ្តោយព្រំដែន ដែលភាគីកម្ពុជា ឡាវ ថៃ និងវៀតណាម បានឯកភាពគ្នាកន្លងមក។

**៥.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តកិច្ចសហការជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) ក្នុងការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(**BLO**)ថ្មី កម្ពុជា-វៀតណាម ចំនួន ២កន្លែង នៅច្រកទ្វារព្រំដែនអន្តរជាតិអូយ៉ាដាវ(ខេត្តរតនគិរី) និងច្រកទ្វារព្រំដែនអន្តរជាតិកោះរការ(ខេត្តព្រៃវែង) ការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(**BLO**) ថ្មី កម្ពុជា-ថៃ ចំនួន ១កន្លែង នៅច្រកទ្វារព្រំដែនអន្តរជាតិជប់គគីរ(ខេត្តឧត្តរមានជ័យ) និងការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(**BLO**)ថ្មី កម្ពុជា-ឡាវ ចំនួន ១កន្លែង នៅច្រកទ្វារព្រំដែនអន្តរជាតិព្រះរំកិល (ស្ទឹងត្រែង) ឲ្យបានចប់ជាស្ថាពរ។

**៥.៤.** បន្តអនុវត្តផែនការសកម្មភាពនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី កម្ពុជា-ថៃ ក្នុងក្របខ័ណ្ឌ LOA (Letter of Agreement) សម្រាប់ខែកញ្ញាឆ្នាំ២០២០។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍនានា

**៦.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយបណ្តាប្រទេសក្នុងតំបន់និងអង្គការដៃគូ ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៦.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ចិន ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**៧.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បន្តនីតិវិធីពិនិត្យខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកជាមួយក្រសួងយុត្តិធម៌។

**៧.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. ត្រៀមផ្សព្វផ្សាយផែនការជាតិ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៧.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. បន្តរៀបចំសេចក្តីព្រាងគោលនយោបាយជាតិសម្រាប់ការបង្កើត ភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន។

**៧.៤.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. បន្តសម្របសម្រួលសហការជាមួយក្រសួងមហាផ្ទៃ រៀបចំបញ្ចូលសមាសភាពគណៈកម្មការភូមិ ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន និងគណៈកម្មការសម្របសម្រួលការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅតាមឃុំ សង្កាត់ ចូលក្នុងគណៈកម្មការភូមិ ឃុំ មានសុវត្ថិភាពគ្រប់លំដាប់ថ្នាក់។

**៧.៥.** ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. និងមន្ត្រីជំនាញត្រៀមចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ឆ្នាំ២០២០ នៅតាមបណ្តារាជធានី-ខេត្ត។

**អគ្គលេខាធិការ**

**នាយឧត្តមសេនីយ៍ មាស-វីរិទ្ធ**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម ជួន សុវណ្ណ អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣
  " ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.៣
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ